# សិទ្ធិរបស់អ្នកនៅអំឡុងពេលប្ដឹងសាទុក្ខ

**<u>សិទ្ធិទទួលបាន "ការជូនដំណឹងគ្រប់គ្រាន់"</u>**
អ្នកមានសិទ្ធិទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរដែលប្រើភាសាធម្មតា ច្បាស់ៗ និងមិនមានលក្ខណៈបច្ចេកទេស។ ការជូនដំណឹងនេះត្រូវតែផ្ដល់ជូនជាភាសាដែលអ្នកចូលចិត្តប្រើ និងជាភាសាដែលអ្នកតំណាងស្របច្បាប់របស់អ្នកចូលចិត្តប្រើ ប្រសិនបើអ្នកមានអ្នកតំណាង។

**<u>សិទ្ធិទទួលបានព័ត៌មានតាមវិធីដែលអ្នកបានជ្រើសរើស</u>**
អ្នកមានសិទ្ធិទទួលបានព័ត៌មានតាមរយៈសំបុត្រ អ៊ីមែល ឬវិធីដទៃទៀតដែលអ្នកជ្រើសរើស។

**<u>សិទ្ធិដាក់បណ្ដឹងសាទុក្ខចំពោះវិធានការ ឬសេចក្ដីសម្រេចដែលបានស្នើឡើងរបស់មជ្ឈមណ្ឌលតំបន់</u>**
អ្នកមានសិទ្ធិដាក់បណ្ដឹងសាទុក្ខប្រសិនបើអ្នកមិនយល់ព្រមចំពោះសេចក្ដីសម្រេច ឬចំណាត់ការណាមួយដែលធ្វើឡើងដោយមជ្ឈមណ្ឌលតំបន់។ សំណើបណ្ដឹងសាទុក្ខត្រូវតែដាក់ក្នុងរយៈពេល 60 ថ្ងៃបន្ទាប់ពីការជូនដំណឹងអំពីការសម្រេច ឬចំណាត់ការ។

**<u>សិទ្ធិរក្សាទុកសេវាបច្ចុប្បន្នរបស់អ្នក</u>**
អ្នកមានសិទ្ធិបន្តលក្ខណៈសម្បត្តិរបស់អ្នក ឬសេវាកម្មនានាដែលអ្នកទទួលនាពេលបច្ចុប្បន្ននៅអំឡុងពេលប្ដឹងសាទុក្ខ។ នេះគេហៅថា "ការបន្តទទួលសេវារហូតដល់ចប់បណ្ដឹង (aid paid pending)"។ រក្សាទុកលក្ខណៈសម្បត្តិ ឬសេវាកម្មរបស់អ្នក សំណើបណ្ដឹងសាទុក្ខរបស់អ្នកត្រូវតែបានទទួលដោយ DDS ឬបោះត្រាប្រៃសនីយ៍រយៈពេល 30 ថ្ងៃបន្ទាប់ពីអ្នកទទួលបានការជូនដំណឹងស្ដីពីវិធានការ (NOA) និងមុនពេលវិធានការកើតឡើង។

**<u>សិទ្ធិចូលប្រើប្រាស់កំណត់ត្រារបស់អ្នក</u>**
អ្នកមានសិទ្ធិចូលប្រើប្រាស់កំណត់ត្រារបស់មជ្ឈមណ្ឌលតំបន់អំពីខ្លួនអ្នក។ នេះមានន័យថាអ្នកអាចមើលកំណត់ត្រាមជ្ឈមណ្ឌលតំបន់របស់អ្នក។ អ្នកក៏អាចទទួលបានច្បាប់ចម្លងកំណត់ត្រារបស់អ្នកផងដែរ។ មជ្ឈមណ្ឌលតំបន់អាចគិតថ្លៃពីអ្នកសម្រាប់តម្លៃថតចម្លងជាក់ស្ដែង។ ប្រសិនបើអ្នកគ្មានប្រាក់បង់សម្រាប់កំណត់ត្រានេះទេ ចូរប្រាប់មជ្ឈមណ្ឌលតំបន់របស់អ្នក និងសាកសួរពីរបៀបទទួលបានច្បាប់ចម្លងនៃកំណត់ត្រារបស់អ្នកដោយឥតគិតថ្លៃ។ អ្នកគួរតែទទួលបានសិទ្ធិចូលប្រើប្រាស់កំណត់ត្រារបស់អ្នកក្នុងរយៈពេល 3 ថ្ងៃធ្វើការបន្ទាប់ពីអ្នកដាក់សំណើ។

**<u>សិទ្ធិសម្រេចក្នុងការចូលរួមរបស់អ្នកក្នុងនីតិវិធីបណ្ដឹងសាទុក្ខ</u>**
អ្នកអាចជ្រើសរើសផ្នែក (នានា) នៃនីតិវិធីបណ្ដឹងសាទុក្ខដែលអ្នកចង់ប្រើប្រាស់។ ជម្រើសរបស់អ្នកមានកិច្ចប្រជុំក្រៅផ្លូវការ ការនាំសម្រុះសម្រួល ឬសវនការ។ អ្នកអាចសម្រេចចិត្តប្រើប្រាស់ផ្នែកណាមួយ ឬទាំងអស់នៃផ្នែកទាំងនេះ។ លើសពីនេះ អ្នកអាចជ្រើសរើសរបៀបចូលរួមក្នុងកិច្ចប្រជុំក្រៅផ្លូវការ កានាំសម្រុះសម្រួល ឬសវនការៈ តាមទូរសព្ទ វីដេអូ ឬដោយផ្ទាល់។ អ្នកអាចកែប្រែសំណើបណ្ដឹងសាទុក្ខរបស់អ្នកនៅពេលណាមួយដើម្បីប្រើប្រាស់នីតិវិធីណាមួយ ឬទាំងអស់នៃនីតិវិធីទាំងអស់។

**សិទ្ធិជ្រើសរើសពេលវេលា និងទីកន្លែងសមស្រប**
អ្នកមានសិទ្ធិជ្រើសរើសកិច្ចប្រជុំក្រៅផ្លូវការ ការនាំសម្រុះសម្រួល និងសវនការតាមពេលវេលា
និងទីកន្លែងដែលអ្នកអាចចូលរួមបាន។

**សិទ្ធិទទួលបានជំនួយ ឬការគាំទ្រ**
អ្នកមានសិទ្ធិឲ្យនរណាម្នាក់ជួយ ឬគាំទ្រអ្នក។ អ្នកនោះអាចជាមេធាវី ឬមនុស្សម្នាក់ទៀត។ គាត់អាចជាអ្នកតំណាងស្របច្បាប់
ឬមិត្តភក្តិ ឬសមាជិកគ្រួសាររបស់អ្នក។ ប្រសិនបើអ្នកយល់ព្រម
អ្នកតំណាងស្របច្បាប់របស់អ្នកនឹងទទួលបានព័ត៌មានអំពីបណ្តឹងសាទុក្ខរបស់អ្នក។

អ្នកអាចស្នើសុំឲ្យមេធាវី ឬនរណាម្នាក់ផ្សេងឲ្យជួយអ្នករៀបចំបណ្តឹងសាទុក្ខរបស់អ្នក។
អ្នកក៏អាចមានមេធាវីចូលរួមក្នុងផ្នែកណាមួយនៃបណ្តឹងរបស់អ្នកផងដែរ។ អ្នកត្រូវតែប្រាប់មជ្ឈមណ្ឌលតំបន់ជាមុន
ប្រសិនបើអ្នកនឹងមានមេធាវីចូលរួមក្នុងកិច្ចប្រជុំក្រៅផ្លូវការ ការនាំសម្រុះសម្រួល ឬសវនការ។
មជ្ឈមណ្ឌលតំបន់មិនអាចមានមេធាវីចូលរួមផ្នែកណាមួយនៃបណ្តឹងសាទុក្ខនេះឡើយប្រសិនបើអ្នកមិនមានមេធាវីចូលរួម
ឬអ្នកគឺជាមេធាវី។

**សិទ្ធិស្នើសុំពេលវេលាបន្ថែម**
ប្រសិនបើអ្នកត្រូវការពេលវេលាថែមទៀត អ្នកអាចស្នើសុំពេលវេលាបន្ថែម។ នេះគេហៅថាការបន្ត។
ការបន្តអាចពន្យារពេលវេលាសម្រាប់ដោះស្រាយបណ្តឹងសាទុក្ខរបស់អ្នក និងត្រូវតែស្នើសុំនៅមុនសវនការត្រូវធ្វើឡើង។

អ្នកស្នើសុំការបន្តជាលើកដំបូង អ្នកមិនចាំបាច់ផ្តល់ហេតុផលឡើយ។ ប្រសិនបើអ្នកស្នើសុំការបន្តថែមទៀត
អ្នកត្រូវផ្តល់ហេតុផល (នេះគេហៅថា "មូលហេតុសមស្រប" សម្រាប់សំណើរបស់អ្នក។

**សិទ្ធិស្នើសុំអ្នកនាំសម្រុះសម្រួល ឬមន្ត្រីសវនការផ្សេង**
អ្នកអាចស្នើសុំអ្នកនាំសម្រុះស្រួល ឬមន្ត្រីសវនការផ្សេង ប្រសិនបើអ្នកគិតថាពួកគេលម្អៀង។
អ្នកត្រូវតែស្នើសុំមុនពេលការនាំសម្រុះសម្រួល ឬសវនការចាប់ផ្តើម និងផ្តល់ហេតុផលសម្រាប់សំណើរបស់អ្នក។

**សិទ្ធិចូលរួមបណ្តឹងសាទុក្ខ**
អ្នកមានសិទ្ធិចូលរួមគ្រប់ផ្នែកទាំងអស់នៃបណ្តឹងសាទុក្ខរបស់អ្នក។

**សិទ្ធិសម្រេចថាតើសវនការនេះបើកចំហចំពោះសាធារណជនដែរឬទេ**
សវនការបើកចំហចំពោះសាធារណជន។ ប្រសិនបើអ្នកមិនចង់ឲ្យសាធារណជនចូលរួមក្នុងសវនការរបស់អ្នកទេ
សូមជម្រាបមន្ត្រីសវនការថាអ្នកមិនចង់ឲ្យសាធារណជនចូលរួមឡើយ។ អ្នកអាចស្នើសុំជាលាយលក្ខណ៍អក្សរនៅមុនពសវនការ
ឬជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់នៅមុនពេលសវនការចាប់ផ្តើម។

**សិទ្ធិទទួលបានសវនការដែលមិនលម្អៀង**
អ្នកមានសិទ្ធិបញ្ចេញមតិដោយសេរី និងដោយចំហនៅក្នុងសវនការ។ មន្ត្រីសវនការនឹងជួយអ្នក
ហើយមជ្ឈមណ្ឌលតំបន់នឹងបង្ហាញអង្គហេតុ។

**សិទ្ធិទទួលបានអ្នកបកប្រែ**
ប្រសិនបើភាសាដែលអ្នកចូលចិត្តប្រើមិនមែនជាភាសាអង់គ្លេស
អ្នកមានសិទ្ធិទទួលបានអ្នកបកប្រែម្នាក់ដែលអាចបកប្រែជូនអ្នកយ៉ាងមានប្រសិទ្ធភាព ត្រឹមត្រូវ និងដោយរលូន។
អ្នកអាចស្នើសុំអ្នកបកប្រែនៅលើទម្រង់សំណើបណ្តឹងសាទុក្ខរបស់អ្នក។
អ្នកបកប្រែនឹងត្រូវផ្តល់ជូនអ្នកសម្រាប់គ្រប់ផ្នែកទាំងអស់នៃបណ្តឹងសាទុក្ខរបស់អ្នក។

**សិទ្ធិផ្តល់ព័ត៌មានដល់មន្ត្រីសវនការ**
អ្នកអាចផ្តល់ជូនមន្ត្រីសវនការនូវព័ត៌មានដែលគាំទ្រដល់បណ្តឹងសាទុក្ខរបស់អ្នក។ ព័ត៌មាននេះគេហៅថាភ័ស្តុតាង។ អ្នក
និងអ្នកផ្សេងដែលអ្នកបានជ្រើសរើសអាចផ្តល់ព័ត៌មានដល់មន្ត្រីសវនការដោយផ្ទាល់មាត់។ អ្នកទាំងនេះគេហៅថាសាក្សី។
អ្នកក៏អាចផ្តល់ឯកសារជាលាយលក្ខណ៍អក្សរដល់មន្ត្រីសវនការផងដែរ។

សេចក្តីថ្លែងបញ្ជាក់ពីតួនាទីរបស់មជ្ឈមណ្ឌលតំបន់ និងភ័ស្តុតាងត្រូវតែធ្វើឡើងជាភាសាដែលអ្នក
និងអ្នកតំណាងស្របច្បាប់របស់អ្នកចូលចិត្តប្រើ ប្រសិនបើអ្នកមានអ្នកតំណាងស្របច្បាប់។
ប្រសិនបើមជ្ឈមណ្ឌលតំបន់មិនអាចផ្តល់ជូននូវកំណែឯកសារបកប្រែទាំងនេះទេ ពួកគេនឹងជូនដំណឹងអ្នក
ផ្តល់ច្បាប់ចម្លងជាភាសាអង់គ្លេស
និងស្នើសុំការបន្តដោយមានការបង្ហាញអំពីកិច្ចខិតខំរបស់ខ្លួនក្នុងការបកប្រែឯកសារទាំងនេះ។
អ្នកត្រូវតែទទួលព័ត៌មាននេះយ៉ាងតិចពីរថ្ងៃធ្វើការនៅមុនសវនការរបស់អ្នក។

**សិទ្ធិក្នុងការចោទសួរសាក្សីរបស់មជ្ឈមណ្ឌលតំបន់**
មជ្ឈមណ្ឌលតំបន់អាចមានសាក្សីចាំផ្តល់សាក្ខីកម្មនៅក្នុងសវនការ។ អ្នកមានសិទ្ធិចោទសួរសាក្សីនោះ។